ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
អនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ កពជ
លេខ:...០០១/ជំ.ក/២០២១...

# ផែនការ

## យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

លេខ...០៤៤...ជ.ក/២០២១

ថ្ងៃព្រហស្បតិ៍ ៣ រោច ខែ ចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០២១

**សច្ចាប័ន**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្ដេចពិជ័យសេនា ទៀ-បាញ់**

- យោងសេចក្តីសម្រេចលេខ ៣៧ ស.ស.រ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ ស្តីពីការបង្កើតគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស
- យោងសេចក្តីសម្រេចលេខ ០១៨ ស.ស.រ ក.ព.ជ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ ស្តីពីការបង្កើតអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្រសួងការពារជាតិ
- យោងសេចក្តីសម្រេចលេខ ០២២ ស.ស.រ ក.ព.ជ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ ស្តីពីការតែងតាំងសមាសភាព តួនាទី និងភារកិច្ចរបស់ក្រុមបច្ចេកទេស និងលេខាធិការដ្ឋាន នៃអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក.ព.ជ
- យោងស្មារតីអង្គប្រជុំថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ស្តីពីយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ

### ក. គោលបំណង និងសំណូមពរ

**១. គោលបំណង៖**

- ចូលរួមយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ដើម្បីបង្កើតភាពស៊ាំក្នុងប្រជាពលរដ្ឋឈានទៅទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ
- ការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនចំពោះប្រជាពលរដ្ឋទូទៅចាប់ពីអាយុ១៨ឆ្នាំឡើង ឱ្យទទួលបានវ៉ាក់សាំងដូសទី១ និងដូសទី២ ទាន់ពេលវេលា។

វិថីហ្សកឌឺមីត្រេវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ : ០២៣ ៨៨៣ ២៧៤ អ៊ីមែល : generalsec@mod.gov.kh

២. សំណូមពរ៖

- រៀបចំផែនការចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងភូមិសាស្ត្រដែលថ្នាក់លើបានកំណត់ឱ្យដល់ប្រជាពលរដ្ឋអាយុ ១៨ឆ្នាំឡើង ឱ្យបានឆាប់រហ័សទាន់ពេលវេលា មានគុណភាព សុវត្ថិភាព សណ្តាប់ធ្នាប់ និងតាមវិធានការ ការពារជំងឺកូវីដ-១៩
- ចាត់តាំងចាក់វ៉ាក់សាំងតាមគោលដៅនីមួយៗឱ្យបានគ្រប់គ្រាន់ និងអប់រំសតិអារម្មណ៍ឃោជិន ដែលចូលរួម ខិតខំអនុវត្ត មិនរញ្ជាក ដើម្បីទទួលបានជោគជ័យ
- ត្រូវសហការជាមួយអាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីប្រតិបត្តិការនេះឱ្យទទួលបានជោគជ័យ។

## ខ.ផែនការ

### ១. គោលដៅ ចាក់វ៉ាក់សាំងកូវីដ-១៩

- ចំនួនប្រជាពលរដ្ឋមូលដ្ឋាន ដែលមានអាយុលើសពី ១៨ឆ្នាំ និងកម្មករនិយោជិតនៅក្នុងខណ្ឌទាំង០៤ នៅក្នុងរាជធានីភ្នំពេញ មានដូចខាងក្រោម៖

| ខណ្ឌ | ប្រជាពលរដ្ឋនៅមូលដ្ឋាន | ចំនួនកម្មករនិយោជិត | ចំនួនសរុបរួម |
|---|---|---|---|
| កំបូល | ៣៥,៦១៥ នាក់ | ៤២,៥៨២ នាក់ | ៧៨,១៩៧ នាក់ |
| ដង្កោ | ៦៧,១៧៩ នាក់ | ៥៧,២៩០ នាក់ | ១២៤,៤៦៩ នាក់ |
| ពោធិ៍សែនជ័យ | ១៣៧,៥១៥ នាក់ | ២៨០,៣៦៣ នាក់ | ៤១៧,៨៧៨ នាក់ |
| មានជ័យ | ១០៨,៣០៨ នាក់ | ៧៦,១៨១ នាក់ | ១៨៤,៤៨៩ នាក់ |
| **សរុប** | **៣៤៨,៦១៧ នាក់** | **៤៥៦,៤១៦ នាក់** | **៨០៥,០៣៣ នាក់** |

- សរុបប្រជាពលរដ្ឋអាយុ១៨ឆ្នាំឡើងមាន ៣៤៨,៦១៧ នាក់ និងកម្មករនិយោជិតចំនួន ៤៥៦,៤១៦ នាក់ សរុបរួម ៨០៥,០៣៣ នាក់ ក្នុងនោះប្រជាពលរដ្ឋ និងកម្មករនិយោជិតដែលបានចាក់វ៉ាក់សាំងរួចហើយ ចំនួន ២៩% = ២៣៣,៤៦០នាក់ ប្រជាពលរដ្ឋ និងកម្មករនិយោជិតមិនទាន់បានចាក់វ៉ាក់សាំងមាន ចំនួន ៥៧១,៥៧៣នាក់ (ក្នុងនោះមិនទាន់បានដកចេញកងទ័ព និងគ្រួសារកងទ័ព ព្រមទាំងកម្មករ និយោជិតដែលបានចាក់វ៉ាក់សាំងរួចហើយ)។

### ២. អំពីវ៉ាក់សាំងកូវីដ-១៩

- រាជរដ្ឋាភិបាល ផ្តល់ជូនតាមរយៈគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ គ្របខណ្ឌទូទាំងប្រទេស មកឱ្យក្រសួងការពារជាតិចំនួន ៩០០,០០០ដូស ក្នុងនោះមាន ស៊ីណូវ៉ាក់ (SINOVAC) ចំនួន ៥០០,០០០ដូស និងស៊ីណូហ្វាម (SINOPHARM ) ចំនួន ៤០០,០០០ ដូស
- ការប៉ាន់ស្មានសេចក្តីត្រូវការវ៉ាក់សាំងនៅក្នុងយុទ្ធនាការចាក់វ៉ាក់សាំងក្នុងខណ្ឌទាំង០៤រួមមាន៖ ១,១៤៣,១៤៦ដូស សម្រាប់ចាក់ជូនមនុស្ស ៥៧១,៥៧៣នាក់ ទាំងដូសទី១ និងដូសទី២
- ការបែងចែកវ៉ាក់សាំងកូវីដ-១៩ សម្រាប់ចាក់
    - ខណ្ឌពោធិ៍សែនជ័យ និងខណ្ឌកំបូល ប្រើប្រាស់វ៉ាក់សាំងស៊ីណូវ៉ាក់ ៥០០,០០០ដូស
    - ខណ្ឌមានជ័យ និងខណ្ឌដង្កោ ប្រើប្រាស់វ៉ាក់សាំងស៊ីណូហ្វាម ៤០០,០០០ ដូស។

### ៣. ពេលវេលាការចាក់វ៉ាក់សាំង

៣.១. ពេលវេលារួមចំនួន៣៨ ថ្ងៃ ក្នុងនោះមាន៖

- ថ្ងៃប្រុងប្រៀបចំនួន ០៣ថ្ងៃ
- ថ្ងៃពិធីបើកចំនួន ០១ថ្ងៃ
- ថ្ងៃយុទ្ធនាការចាក់វ៉ាក់សាំង ដូសទី១ និងដូសទី២ ចំនួន ៣០ថ្ងៃ
- ថ្ងៃបម្រុងចំនួន ០៤ ថ្ងៃ

៣.២. ប្រតិទិនការងារ

- ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ប្រជុំទទួលផែនការ និងចុះពិនិត្យភូមិសាស្ត្រ
- ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២១ ប្រជុំផ្សព្វផ្សាយផែនការ យុទ្ធនាការចាក់វ៉ាក់សាំង
- ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១ - ទទួលវ៉ាក់សាំងចូលឃ្លាំងក្រសួងការពារជាតិ
  -ចុះពិនិត្យភូមិសាស្ត្រ និងទំនាក់ទំនងជាមួយមូលដ្ឋាន
  -កងឯកភាពរៀបចំផែនការចាក់វ៉ាក់សាំង
  (បែងចែកក្រុមចាក់វ៉ាក់សាំង និងរៀបចំកម្មវិធីចាក់)
- ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១ រៀបចំពិធីប្រកាស បើកយុទ្ធនាការចាក់វ៉ាក់សាំង (ធ្វើនៅកងពលតូចលេខ ៧០)
- ថ្ងៃទី០១ ដល់ ១៥ ខែឧសភា ឆ្នាំ២០២១ ចាក់វ៉ាក់សាំងដូសទី១
- ថ្ងៃទី១៦ ដល់ ៣១ ខែឧសភា ឆ្នាំ២០២១ ចាក់វ៉ាក់សាំងដូសទី២។

**៤. ការចាក់វ៉ាក់សាំងកូវីដ-១៩**

៤.១ កំលាំងកងយោធពលខេមរៈភូមិន្ទចូលរួមក្នុងយុទ្ធនាការចំនួន ១៤៩០នាក់ ក្នុងនោះមាន៖

- ការរៀបចំក្រុមចាក់វ៉ាក់សាំងមានចំនួន ៩០ក្រុម ក្នុងមួយក្រុម ០៥នាក់ សរុបចំនួន ៤៥០នាក់
- ក្រុមបម្រើការ និងសណ្ដាប់ធ្នាប់ចំនួន ៩០ក្រុម ក្នុងមួយក្រុម ១០នាក់ សរុបចំនួន ៩០០នាក់
- ក្រុមដឹកជញ្ជូនចំនួន ១០ក្រុម ក្នុងមួយក្រុម ០៥នាក់ សរុបចំនួន ៥០នាក់
- ក្រុមធ្វើបណ្ណចាក់វ៉ាក់សាំងចំនួន ៩០នាក់
- កងឯកភាពចូលរួមមាន៖ កងទ័ពជើងគោកមានចំនួន ០៥កងឯកភាព(សុខាភិបាល ក.ជ.គ, កងពលតូចលេខ៧០, យោធភូមិភាគពិសេស, បញ្ជាការដ្ឋានទ័ពពិសេស, និងបញ្ជាការដ្ឋានការពារអាកាស ក.ជ.គ)
- អគ្គបញ្ជាការដ្ឋាន ទីចាត់ការសុខាភិបាល, បញ្ជាការដ្ឋានវិស្វកម្ម, បញ្ជាការដ្ឋានកាំភ្លើងធំ, បញ្ជាការដ្ឋានបញ្ជូនសារ អ.ប.ក, កងទ័ពជើងទឹក, កងទ័ពជើងអាកាស, កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងនាយកដ្ឋានសុខាភិបាលក្រសួងការពារជាតិ

៤.២ ត្រូវរៀបចំកន្លែងចាក់ ទៅតាមសង្កាត់ ឬទៅតាមដង់ស៊ីតេ របស់ប្រជាពលរដ្ឋ

- ចំពោះតំបន់ត្រូវរៀបចំកន្លែងចាក់វ៉ាក់សាំងនៅគៀកជាមួយប្រជាពលរដ្ឋ ឬតាមភូមិ
- ការរៀបចំកន្លែងត្រូវមាន៖ ទីតាំងរង់ចាំទី១ និងទី២, ទីតាំងចាក់វ៉ាក់សាំង (ពិនិត្យកំដៅ, សម្ភាសន៍, ចាក់វ៉ាក់សាំង, កត់ត្រា, សង្គ្រោះ) ទីតាំងរង់ចាំក្រោយចាក់រួច
  - ❖ ត្រូវអនុវត្តតាមវិធានការណ៍ការពារជំងឺកូវីដ-១៩ ឱ្យបានដាច់ខាត

៤.៣ ការចាក់វ៉ាក់សាំង

- ត្រូវចាក់ចំពោះប្រជាពលរដ្ឋទាំងពីរភេទ មានអាយុ១៨ឆ្នាំឡើងទៅ
- ចាក់ជូនប្រជាពលរដ្ឋទូទៅ ព្រះសង្ឃ និងជនបរទេសដែលស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ចំពោះអ្នកដែលមិនត្រូវចាក់រួមមាន៖ អ្នកដែលបានចាក់វ៉ាក់សាំងរួចហើយ, អ្នកដែលពេទ្យសម្រេចមិនឱ្យចាក់ ដោយបញ្ហាសុខភាព
- អ្នកដែលទទួលវ៉ាក់សាំងដូសទី១ និងដូសទី២ តែប្រភេទវ៉ាក់សាំងតែមួយ
- វិធីសាស្ត្រត្រូវប្រមូលផ្តុំតំបន់ ឬកន្លែងនីមួយៗឱ្យបានអស់ ទើបទៅកកន្លែងផ្សេងទៀត

៤.៤ ចំពោះក្រុមពេទ្យរបស់រាជធានីភ្នំពេញ និងក្រសួងការងារ ត្រូវបន្តចាក់ដូសទី២ ជូនកម្មករនយោជិតណាដែលបានចាក់ដូសទី១រួចហើយ។

## ៥. ការទទួលខុសត្រូវ

៥.១ អង្គភាពទទួលខុសត្រូវ

- កងទ័ពជើងគោក ទទួលខុសត្រូវចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងខណ្ឌពោធិ៍សែនជ័យ និងខណ្ឌមានជ័យ
- កងទ័ពជើងទឹក និងកងទ័ពជើងអាកាស ទទួលខុសត្រូវចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងខណ្ឌដង្កោ
- កងរាជអាវុធហត្ថលើផ្ទៃប្រទេស ទីចាត់ការសុខាភិបាល អ.ប.ក,បញ្ជាការដ្ឋានវិស្វកម្ម បញ្ជាការដ្ឋានកាំភ្លើងធំ បញ្ជាការដ្ឋានបញ្ជូនសារ និងនាយកដ្ឋានសុខាភិបាល ក.ព.ជ ទទួលខុសត្រូវចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងខណ្ឌកំបូល

៥.២ ការចាត់តាំងទទួលខុសត្រូវ

- តាមកងឯកភាពនីមួយៗត្រូវចាត់តាំងនាយទាហានទទួលខុសត្រូវ ជាប្រធានមណ្ឌលចាក់វ៉ាក់សាំង និងទទួលខុសត្រូវតាមផ្នែកជំនាញនីមួយៗ ក្នុងមណ្ឌលចាក់វ៉ាក់សាំង
- កងឯកភាពអាចរៀបចំក្រុមគ្រូពេទ្យ ឬកងឯកភាពនីមួយៗទទួលខុសត្រូវតាមសង្កាត់ ឬភូមិ

៥.៣ ក្រសួងការងារត្រូវសហការជាមួយក្រុមចាក់វ៉ាក់សាំងកងយោធពលខេមរភូមិន្ទ ក្នុងយុទ្ធនាការចាក់វ៉ាក់សាំងនេះដូចជា៖ ផ្តល់ទិន្នន័យ ឬទូរលេខកម្មករនិយោជិត, ទីតាំងរោងចក្រ ឬកន្លែងស្នាក់នៅកម្មករ, សហការរៀបចំទីតាំងចាក់វ៉ាក់សាំងនិងសម្របសម្រួលជាមួយរោងចក្រ ព្រមទាំងស្ថានភាពផ្សេងៗអំពីកម្មករនិយោជិត ព្រមទាំងសហការរៀបចំសណ្តាប់ធ្នាប់ឱ្យមានលំដាប់លំដោយ សម្រាប់កម្មករនយោជិតដែលមកចាក់វ៉ាក់សាំង

៥.៤ រដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌ និងក្រុមប្រឹក្សាសង្កាត់

- ត្រូវផ្តល់ទិន្នន័យ ឬតួលេខប្រជាពលរដ្ឋក្នុងមូលដ្ឋាននីមួយៗ
- សហការរៀបចំទីតាំងចាក់វ៉ាក់សាំង
- ចាត់តាំងក្រុមអំពាវនាវ ឱ្យប្រជាពលរដ្ឋមកចាក់វ៉ាក់សាំង ចង្អុលបង្ហាញនិងកំណត់ឱ្យក្រុមចាក់វ៉ាក់សាំងចាក់ជូនប្រជាជនក្នុងមូលដ្ឋានរបស់ខ្លួន
- ចូលរួមរៀបចំសណ្តាប់ធ្នាប់ តាមវិធានការការពារជំងឺកូវីដ-១៩ និងលំដាប់លំដោយសម្រាប់ប្រជាពលរដ្ឋចូលចាក់វ៉ាក់សាំង
- ក្រុមប្រឹក្សាសង្កាត់ និងមេភូមិ ត្រូវកំណត់ប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រជួបការលំបាក ដើម្បីចែកជូនអំណោយ របស់**សម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** (ចំពោះតំបន់ក្រហម) .
- សហការរៀបចំឯកសារ ឬការបំពេញទម្រង់ចាក់វ៉ាក់សាំង និងប្រមូលឯកសារដែលបានចាក់វ៉ាក់សាំងទាំង២ដូសរួច សម្រាប់ធ្វើបណ្ណ និងចែកបណ្ណជូនប្រជាពលរដ្ឋ

៥.៥ គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្របខណ្ឌទូទាំងប្រទេស ត្រូវចូលរួមផ្តល់យោបល់ អំពីលក្ខណៈបច្ចេកទេស អំពីការប្រើប្រាស់ វ៉ាក់សាំង ការចាក់វ៉ាក់សាំង កត់ត្រា និងជួយផ្តល់ខោអាវការពារដល់ក្រុមគ្រូពេទ្យ តាមសំណើរបស់ក្រសួងការពារជាតិ .

៥.៦ ឧត្តមសេនីយ៍ឯក **ខឹម សន** និងឧត្តមសេនីយ៍ឯក **ច័ន្ទ សុភក្រ្តា** ត្រូវសហការជាមួយអាជ្ញាធរដែនដីពិសេសក្រុមប្រឹក្សាសង្កាត់ក្នុងតំបន់ក្រហម និងបញ្ជាការដ្ឋានអង្គរក្ស ដឹកជញ្ជូនអំណោយរបស់**សម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** សម្រាប់ចែកជូនប្រជាពលរដ្ឋ នៅតាមគោលដៅកំណត់

៥.៧ លេខាធិការដ្ឋាន អនុគណៈកម្មការចំពោះកិច្ច ក.ព.ជ ត្រូវបូកសរុបរបាយការណ៍ លទ្ធផលចាក់វ៉ាក់សាំងជារៀងរាល់ថ្ងៃ សម្រាប់រាយការណ៍ជូនប្រធានអនុគណៈកម្មការចំពោះកិច្ចរាយការណ៍ជូន **សម្តេចពិជ័យសេនា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ។

## ៦. ការងារអប់រំ និងឃោសនាព័ត៌មាន

- ត្រូវផ្សព្វផ្សាយតាមទូរទស្សន៍ សារព័ត៌មានផ្សេងៗ និងឃោសនាអំពីការចាក់វ៉ាក់សាំង គុណប្រយោជន៍ និងបកស្រាយ ឬវាយបកវាល់មតិប្រឆាំង
- ចុះយកព័ត៌មានអំពីសកម្មភាពរបស់កងយោធពលខេមរភូមិន្ទ និងសម្ភាសន៍ចំពោះយោធិន និងអ្នកចាក់វ៉ាក់សាំង រំលេចពីស្នាដៃរបស់កងយោធពលខេមរភូមិន្ទជាប្រវត្តិសាស្ត្រ
- បង្កើត Group Telegram និងចាត់តាំងនាយទាហានសម្រាប់ដោះស្រាយសំនួររបស់ប្រជាពលរដ្ឋ និងបកស្រាយរាល់ចម្ងល់ផ្សេងៗ។

## ៧. ការងារធានា

- គ្រប់កងឯកភាព ត្រូវកំណត់ចំនួនទីតាំងចាក់វ៉ាក់សាំង និងលើកគម្រោងអំពីការចំណាយ លើការរៀបចំទីតាំង និងការឧបត្ថម្ភដល់យោធិនចូលរួមក្នុងយុទ្ធនាការចាក់វ៉ាក់សាំងនេះ
- នាយកដ្ឋានសុខាភិបាល ត្រូវបោះពុម្ពទម្រង់បែបបទចាក់វ៉ាក់សាំង ចែកជូនតាមទីតាំងចាក់វ៉ាក់សាំង
- អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ត្រូវធានា ប្រេងឥន្ធនៈ ថវិកា ការដឹកជញ្ជូនវ៉ាក់សាំងដល់គ្រប់គោលដៅ និងថែរក្សាវ៉ាក់សាំងតាមលក្ខណៈបច្ចេកទេស
- បូកសរុបការចំណាយ ស្នើសុំថវិកាដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៨. វិធានការប្រតិបត្តិការចាក់វ៉ាក់សាំង

- ត្រូវរៀបចំទីតាំងចាក់វ៉ាក់សាំងតាមលក្ខណៈបច្ចេកទេស និងតាមភូមិសាស្ត្រដែលស្ថិតនៅជិតប្រជាពលរដ្ឋ ជាពិសេសតំបន់ក្រហម
- ត្រូវបំពាក់ជូនយោធិនដែលប្រតិបត្តិការចាក់វ៉ាក់សាំងដូចជា ខោអាវការពារ ម៉ាស់ របាំងមុខការពារ ស្រោមដៃការពារ ។ល។
- ត្រូវណែនាំឱ្យយោធិនទាំងអស់អនុវត្ត វិធានការការពារជំងឺកូវីដ-១៩ (ដោយហេតុថា ក្នុងចំណោមប្រជាពលរដ្ឋដែលត្រូវចាក់វ៉ាក់សាំង ពុំមានព័ត៌មានច្បាស់លាស់អំពីសភាពជំងឺកូវីដ-១៩ ឡើយ)
- យោធិនម្នាក់ៗត្រូវប្តេជ្ញាការពារមិនឱ្យឆ្លងជំងឺកូវីដ-១៩។

## ៩. ការធ្វើបណ្ណចាក់វ៉ាក់សាំង

- គ្រប់ទីកន្លែងចាក់វ៉ាក់សាំង ក្រោយពីការចាក់ដូសទី២រួច ត្រូវសហការជាមួយអាជ្ញាធរ ប្រមូលយកឯកសារពាក់ព័ន្ធ និងរូបថត ធ្វើបណ្ណជូនប្រជាពលរដ្ឋ
- ត្រូវបញ្ចូលក្នុងទិន្នន័យ បើកងយោធពខេមរភូមិន្ទចាក់ជូនប្រជាពលរដ្ឋ ត្រូវចេញបណ្ណរបស់កងយោធពលខេមរភូមិន្ទ ជូនប្រជាពលរដ្ឋ និងត្រូវធ្វើឱ្យបានទាន់ពេលវេលា។

# គ. វិធានការអនុវត្ត

## ១. អំពីរបៀបរបបធ្វើការងារ

- ក្រុមការងារចាក់វ៉ាក់សាំងត្រូវធ្វើផែនការរួមដើម្បីរាយការណ៍ជូនប្រធានអនុគណៈកម្មការ និងរាយការណ៍សុំមតិយោបល់ពី **សម្តេចពិជ័យសេនា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ
- ក្រុមការងារចាក់វ៉ាក់សាំង ត្រូវរៀបចំចាត់ចែងការងារប្រចាំថ្ងៃ តាមផែនការរួម ដែលបានអនុម័តរួច
- គ្រប់កងឯកភាពត្រូវធ្វើផែនការអំពីទីកន្លែងចាក់វ៉ាក់សាំងនីមួយៗ ដោយអនុវត្តតាមផែនការរួមរបស់អនុគណៈកម្មការចំពោះកិច្ច

- គ្រប់កងឯកភាពត្រូវរាយការណ៍អំពីសកម្មភាព លទ្ធផល និងវាយតម្លៃស្ថានភាពទូទៅ ក្នុងពេលប្រតិបត្តិការចាក់វ៉ាក់សាំងជារៀងរាល់ថ្ងៃ វេលាម៉ោង១៧៖០០ ដល់ ១៨៖០០ និងពេលចប់យុទ្ធនាការត្រូវធ្វើការបូកសរុបដកពិសោធន៍ រាយការណ៍មកអនុគណៈកម្មការចំពោះកិច្ច
- ការទំនាក់ទំនងតាមប្រព័ន្ធ Telegram ក្នុងករណីចាំបាច់ ត្រូវទាក់ទងដោយផ្ទាល់
- ការប្រជុំប្រព្រឹត្តតាមប្រព័ន្ធខ្សែគមនាគមន៍ ZOOM ។

**២. ការដឹកនាំ**

- ប្រធានអនុគណៈកម្មការចំពោះកិច្ចក្រសួងការពារជាតិ ទទួលការងារដឹកនាំរួម
- នាយឧត្តមសេនីយ៍ **ឥត សារ៉ាត់** អនុប្រធានគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក.ព.ជ ទទួលខុសត្រូវដឹកនាំបញ្ជា ប្រតិបត្តិការ យុទ្ធនាការចាក់វ៉ាក់សាំងក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ តាមផែនការនេះ
- នាយឧត្តមសេនីយ៍ **ម៉ក់ សារុន** ប្រធានក្រុមការងារ ទទួលខុសត្រូវចាត់ចែងការងារប្រចាំថ្ងៃតាមផែនការនេះ
- គ្រប់កងឯកភាពដែលមានភារកិច្ចចូលរួមត្រូវចាត់តាំងក្រុមគ្រូពេទ្យតាមផែនការ និងអនុវត្តន៍តាមតួនាទីប្រគល់ឱ្យ
- ចាត់តាំង ឧត្តមសេនីយ៍ទោ **ប៉ែន សុក្រិត្យវិទ្យា** ជាអ្នកទំនាក់ទំនង និងសម្របសម្រួលរាល់ការងារ ដែលមានទូរស័ព្ទលេខ ០៩៧ ៥០១ ៦៦៦៦, ០១២ ៤៣៧ ៨៨៨។

ក្រោយពីទទួលបានផែនការ នាយទាហាន និងកងឯកភាពពាក់ព័ន្ធ ត្រូវធ្វើការជ្រួតជ្រាប និងចាត់តាំងអនុវត្តឱ្យបានជោគជ័យ៕

ថ្ងៃព្រហស្បតិ៍ ៣ រោច ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០២១

**ប្រធានអនុគណៈកម្មការចំពោះកិច្ច**
**ចាក់វ៉ាក់សាំង កូវីដ-១៩ ក.ព.ជ**

**នាយឧត្តមសេនីយ៍.នាង_ផាត**

**ប្រធានប្រតិបត្តិការយុទ្ធនាការចាក់វ៉ាក់សាំង**

**នាយឧត្តមសេនីយ៍.ឥត_សារ៉ាត់**